**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៦-២២០ ប្រ.ក

លិខិតចូល
ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ20០៦

# ប្រកាស
## ស្តីពី
## ប្រតិបត្តិការនៃគណនីទូទាត់

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម ០១៩៦ / ២៧ ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម ១០០៥ / ០៣០ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាននៃធនាគារជាតិនៃកម្ពុជា
- យោងតាមការអនុម័តរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៦

## សំរេច

**ប្រការ ១.-**

និយមន័យនៃពាក្យដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិ-ការទូទាត់សងប្រាក់ត្រូវបានបញ្ចូលក្នុងប្រកាសនេះ លើកលែងតែពាក្យមួយចំនួនដូចខាងក្រោម ឬនៅក្នុងបរិការណ៍ណាដែលតម្រូវឱ្យមានន័យផ្សេងពីនេះ ÷

១- **ធនាគារ** សំដៅដល់ធនាគារ ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុន្តែមិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា។

២- **ការទូទាត់សងប្រាក់ធនាគារទ្វេភាគី** សំដៅដល់ការទូទាត់ពីធនាគារមួយទៅធនាគារមួយផ្សេងទៀត ។

៣- **ការទូទាត់** សំដៅដល់ដំណើរការទូទាត់ចេញពី ឬចូលក្នុងគណនីទូទាត់ ។

៤- **ការទូទាត់សងប្រាក់ធនាគារតែមួយ** សំដៅដល់ការទូទាត់សងប្រាក់រវាងធនាគារ និងធនាគារជាតិនៃកម្ពុជា ។

៥- **អ្នកដំណើរការតតិយភាគី** សំដៅដល់អ្នកផ្ដល់មធ្យោបាយសំរាប់ដំណើរការបញ្ជាទូទាត់ក្នុងនាមធនាគារ ។

**ប្រការ ២.-**

១- ការផាត់ទាត់និងការទូទាត់នឹងធ្វើឡើងរាល់ថ្ងៃធ្វើការ របស់ធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះដូរបញ្ជាទូទាត់ដែលពាក់ព័ន្ធនឹងការទូទាត់សងប្រាក់ធនាគារតែមួយ និងទ្វេភាគី ។

២- ដើម្បីចូលរួមក្នុងការផាត់ទាត់និងការទូទាត់ បញ្ជាទូទាត់អន្តរធនាគារមួយនឹងឆ្លុះបញ្ចាំងពីប្រតិបត្តិ-ការទូទាត់ក្នុងនាមអតិថិជនម្នាក់ ឬធនាគារចូលរួមមួយ ។ បញ្ជាទូទាត់ដែលបានប្រគល់ដោយផ្ទាល់ពីអតិថិជនទៅអ្នកដំណើរការតតិយភាគីតាមការបញ្ជារបស់ធនាគារខ្លួន ត្រូវបានចាត់ទុកជាបញ្ជាទូទាត់ផ្ទាល់របស់ធនាគារដែលអនុវត្តតាមបញ្ជារបស់អតិថិជន ។

៣- អ្នកចូលរួមក្នុងការផាត់ទាត់និងការទូទាត់គឺជាធនាគារ ។ ការទូទាត់អន្តរធនាគារនៃការផាត់ទាត់ធ្វើឡើងនៅលើគណនីទូទាត់របស់ធនាគារដែលរក្សានៅធនាគារជាតិនៃកម្ពុជា ។

៤- ធនាគារត្រូវគោរពតាមប្រកាសនេះ និងនីតិវិធីប្រតិបត្តិការនានាក៏ដូចជាបទប្បញ្ញត្តិដែលមានចែងនៅក្នុងប្រការជាបន្តបន្ទាប់ទៅនេះ ។

៥- ប្រកាសនេះអនុវត្តតែចំពោះការផ្ទេរឥណទាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងគណនីទូទាត់ជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ ។

**ប្រការ ៣.-**

១- ដើម្បីអាចបញ្ចូលទៅក្នុងការទូទាត់បាន បញ្ជាទូទាត់នីមួយៗត្រូវតែសំរាប់ការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគីចេញពី និង/ឬ ចូលក្នុងគណនីទូទាត់ ។ បញ្ជាទូទាត់ត្រូវមានចែងសេចក្ដីណែនាំដោយគ្មានល័ក្ខខ័ណ្ឌនិងមិនអាចបដិសេធបានចំពោះការទូទាត់ជាប្រាក់រៀល និង ប្រាក់ដុល្លារអាមេរិក ហើយមិនត្រូវស្ថិតនៅក្រោមការរឹតត្បិត ឬការដាក់កម្រិតណាឡើយ លើកលែងតែបញ្ជាទូទាត់នេះ មានកំណត់ថ្ងៃប្រសិទ្ធភាព ដូចបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ ។ បញ្ជាទូទាត់ ត្រូវ

គោរពតាមលក្ខណៈជាក់លាក់ដូចដែលបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ និងត្រូវបញ្ជូនទៅធនាគារណាមួយ ឬធនាគារជាតិនៃកម្ពុជា។

២- ក្រោមបទប្បញ្ញត្តិនៃប្រកាសនេះ បញ្ជាទូទាត់ដែលគោរពតាមកថាខណ្ឌទី១ នៃប្រការនេះនឹងត្រូវអនុវត្តដោយធនាគារជាតិនៃកម្ពុជា តាមការចុះឥណពន្ធនិង/ឬឥណទានក្នុងគណនីទូទាត់។ បញ្ជាទូទាត់ដែលមិនគោរពតាមកថាខណ្ឌទី១ នៃប្រការនេះ ឬមិនអាចបញ្ជូនបានដោយសារទិន្នន័យ មិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវ មិនអាចបញ្ជាក់យថាភូតបាន ឬហេតុផលផ្សេងទៀត ព្រមទាំងបញ្ជាទូទាត់នីមួយៗដែលបានធ្វើខុសអាសយដ្ឋាន ត្រូវតែបញ្ជូនត្រឡប់ទៅធនាគារផ្ញើវិញដោយអនុលោមតាមលេខកូដតែមួយដែលបានជ្រើសយកសំរាប់ផ្ញើត្រឡប់វិញនេះ ដែលផ្តល់ដោយធនាគារចូលរួមនីមួយៗ។

**ប្រការ ៤.-**

រាល់ធនាគារកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជាដែលមានបំណងចូលរួមក្នុងការទូទាត់បញ្ជាទូទាត់ក្នុងស្រុក ត្រូវបើកនិងរក្សាគណនីទូទាត់ក្នុងបញ្ជីរបស់ធនាគារជាតិនៃកម្ពុជា ហើយត្រូវបើកនិងដាក់ឱ្យដំណើរការនូវគណនីនោះតាមល័ក្ខខ័ណ្ឌ និងការកំណត់ដូចដែលបានសំរេចដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥.-**

១- ចំពោះរាល់ធនាគារ ការទូទាត់សងប្រាក់នីមួយៗដូចខាងក្រោមដែលផ្តើមឡើងដោយបញ្ជាទូទាត់អាចត្រូវបានធ្វើឡើងដោយបញ្ចូលទៅក្នុង និងដកចេញពីគណនីទូទាត់ ÷

ក- ការទូទាត់សងប្រាក់ធនាគារតែមួយ

ខ- ការទូទាត់សងប្រាក់ធនាគារទ្វេភាគី

២- ធនាគារជាតិនៃកម្ពុជានឹងមិនចុះឥណពន្ធគណនីទូទាត់ ឬអនុញ្ញាតឱ្យដកសាច់ប្រាក់ចេញពីគណនីនេះទេ លុះត្រាតែមានសមតុល្យគ្រប់គ្រាន់ដើម្បីធានាចំនួនឥណពន្ធ ឬការដកប្រាក់។

៣- ការទូទាត់សងប្រាក់ធនាគារតែមួយ ដូចជាការដកសាច់ប្រាក់ ឬការដាក់ប្រាក់បញ្ញើនឹងត្រូវបានចុះកិច្ចបញ្ជិកាដោយធនាគារជាតិនៃកម្ពុជាទៅក្នុងគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ចេញពីគណនីទូទាត់នៅធនាគារជាតិនៃកម្ពុជា ត្រូវបានធ្វើឡើងតាមរយៈការចុះឥណពន្ធចំពោះគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ដោយធនាគារជាតិនៃកម្ពុជាចូលក្នុងគណនីទូទាត់ត្រូវធ្វើឡើងតាមរយៈការចុះឥណទានចំពោះគណនីទូទាត់របស់ធនាគារ។ ការទូទាត់សងប្រាក់ក្នុងធនាគារតែមួយនឹងក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាន នៅពេលណាបានចុះកិច្ចបញ្ជិកាខ្ទង់ឥណពន្ធ និងឥណទាននោះចូលក្នុងគណនីទូទាត់របស់ធនាគារ។

៤- ការទូទាត់សងប្រាក់ធនាគារទ្វេភាគីអាចផ្តួចផ្តើមឡើងដោយបញ្ជាទូទាត់ទៅកាន់ធនាគារជាតិនៃកម្ពុជា ដើម្បីចុះឥណពន្ធគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់ និងចុះឥណទានគណនីទូទាត់របស់ធនាគារមួយទៀត។ ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងតាមរយៈការចុះឥណពន្ធគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់ និងចុះឥណទានព្រមគ្នាលើគណនីទូទាត់របស់ធនាគារមួយផ្សេងទៀត។ ការទូទាត់សងប្រាក់ធនាគារទ្វេភាគីនឹងក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាន នៅពេលណាបានចុះកិច្ចបញ្ជិកាខ្ទង់ឥណពន្ធ និងឥណទាននោះចូលក្នុងគណនីទូទាត់របស់ធនាគារ។

៥- លិខិតបញ្ជាក់តាមរយៈការជូនដំណឹងពីការចុះកិច្ចបញ្ជិកាខ្ទង់ឥណពន្ធ ឬឥណទានទៅក្នុងគណនីទូទាត់ នៅក្រោមកថាខណ្ឌនេះ ត្រូវផ្ញើដោយធនាគារជាតិនៃកម្ពុជាទៅកាន់ធនាគារដែលចូលរួមនៅក្នុងការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគីនោះ។ ការជូនដំណឹងត្រូវធ្វើឡើងភ្លាមបន្ទាប់ពីការបញ្ចប់ការផាត់ទាត់ប្រចាំថ្ងៃ ដូចដែលបានកំណត់ក្នុងនីតិវិធីប្រតិបត្តិការ។

៦- ខ្ទង់ឥណពន្ធចំពោះការដកសាច់ប្រាក់ដោយធនាគារ ត្រូវតែបានចុះកិច្ចបញ្ជិកាជាបន្ទាន់ដោយធនាគារជាតិនៃកម្ពុជា ទៅក្នុងគណនីទូទាត់របស់ធនាគារនោះភ្លាមបន្ទាប់ពីការដកសាច់ប្រាក់។

៧- ចំពោះរាល់ប្រតិបត្តិការទូទាត់សងប្រាក់ ការទូទាត់ត្រូវបានបញ្ចប់នៅពេលណាដែលលទ្ធផលនៃខ្ទង់ឥណពន្ធ ឬខ្ទង់ឥណទាននៃការទូទាត់នោះត្រូវបានចុះកិច្ចបញ្ជិកាក្នុងគណនីទូទាត់របស់ធនាគារជាភាគីនៃការទូទាត់សងប្រាក់បានក្លាយជាស្ថាពរ មិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាន។

## ប្រការ ៦.-

១- បញ្ជាទូទាត់ដែលបញ្ជាឱ្យធនាគារជាតិនៃកម្ពុជាអនុវត្តការទូទាត់សងប្រាក់ធនាគារតែមួយ ឬទ្វេភាគីអាចត្រូវបានប្រគល់ដោយធនាគារទៅឱ្យធនាគារជាតិនៃកម្ពុជា ជាបញ្ជាទូទាត់មួយៗដោយឡែក ឬជាផ្នែកនៃសំណុំមួយ។

២- ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តការទូទាត់ចំពោះបញ្ជាទូទាត់នីមួយៗ ដែលបានបញ្ជូនមក ÷

- តែនៅពេលណាដែលគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់មានមូលនិធិគ្រប់គ្រាន់ប៉ុណ្ណោះ និង
- នៅពេលណាមួយមុនពេលបញ្ចប់ការផាត់ទាត់ប្រចាំថ្ងៃ ដូចដែលបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិការ។

ចំពោះបញ្ជាទូទាត់មានថ្ងៃប្រសិទ្ធភាព ដូចដែលបានចែងក្នុងនីតិវិធីប្រតិបត្តិការ ពេលវេលានៃការអនុវត្តបញ្ជាទូទាត់នោះត្រូវតែនៅថ្ងៃប្រសិទ្ធភាព។

៣- នៅពេលណាដែលមូលនិធិនៃគណនីធនាគារទូទាត់សងប្រាក់ពុំមានគ្រប់គ្រាន់សំរាប់ទូទាត់ ធនាគារជាតិនៃកម្ពុជាអាចបដិសេធ ឬដាក់បញ្ជាទូទាត់ឱ្យស្ថិតក្នុងការរង់ចាំ ហើយផ្តល់ដំណឹងដល់ធនាគារបញ្ជានោះ ។ បញ្ជាទូទាត់ដែលបានដាក់ឱ្យស្ថិតក្នុងការរង់ចាំនឹងត្រូវអនុវត្តដោយធនាគារជាតិនៃកម្ពុជាទៅតាមលំដាប់នៃការរង់ចាំ និងដោយគ្មានការជូនដំណឹងជាមុន លុះត្រាតែគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់មានមូលនិធិគ្រប់គ្រាន់ ។ ធនាគារជាតិនៃកម្ពុជា អាចបដិសេធបញ្ជាទូទាត់ដែលមិនទាន់ត្រូវបានអនុវត្តនៅពេលណាក៏បាន មុនពេលបញ្ជាទូទាត់នេះត្រូវបានអនុវត្ត ហើយនឹងផ្តល់ដំណឹងដល់ធនាគារបញ្ជានោះ ។ បញ្ជាទូទាត់របស់ធនាគារដែលមិនត្រូវបានអនុវត្ត និងបដិសេធក្នុងអំឡុងពេលផាត់ទាត់ប្រចាំថ្ងៃនឹងត្រូវបានលុបចោលតាមការកំណត់ដោយឡាប់នៅចុងបញ្ចប់នៃការផាត់ទាត់ប្រចាំថ្ងៃដូចមានចែងក្នុងនីតិវិធីប្រតិបត្តិការ ។

៤- ចំពោះគោលបំណងនៃកថាខណ្ឌខាងលើ នៅពេលណាមានមូលនិធិមិនគ្រប់គ្រាន់សំរាប់សំណុំបញ្ជាទូទាត់ ធនាគារជាតិនៃកម្ពុជាអាចចាត់ទុកបញ្ជាទូទាត់នីមួយៗក្នុងសំណុំនោះជាបញ្ជាទូទាត់ដែលបញ្ជូនមកដាច់ដោយឡែកៗពីគ្នា ។ ធនាគារជាតិនៃកម្ពុជាត្រូវចាត់ចែងបញ្ជាទូទាត់នីមួយៗនោះសំរាប់អនុវត្តទៅតាមមូលនិធិដែលមានដោយការដាក់បន្តគ្នា ឬបដិសេធទៅតាមលំដាប់សមស្រប ។

៥- លើកលែងតែមានការបដិសេធ ឬការដាក់ឱ្យស្ថិតក្នុងការរង់ចាំបន្តគ្នាដោយធនាគារជាតិនៃកម្ពុជាដូចបានចែងក្នុងកថាខណ្ឌទី៣ខាងលើ បញ្ជាទូទាត់របស់ធនាគារដែលបានប្រគល់ឱ្យធនាគារជាតិនៃកម្ពុជានឹងមិនអាចបដិសេធបាន និងលុបចោលបានដោយធនាគារនោះឡើយ ។ ចំពោះបញ្ជាទូទាត់ដែលស្ថិតក្នុងការរង់ចាំ ការលុបចោលដោយធនាគារបញ្ជានឹងមានប្រសិទ្ធភាព លុះត្រាតែបានជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជាតាមរបៀប ពេលវេលា និងអនុលោមតាមនីតិវិធីដែលបានចែង និងអនុម័តដោយធនាគារជាតិនៃកម្ពុជាតែប៉ុណ្ណោះ ដែលបង្កលក្ខណៈឱ្យធនាគារជាតិនៃកម្ពុជាអាចចាត់វិធានការមុនមានការចុះឥណពន្ធគណនីទូទាត់របស់ធនាគារ ។

៦- ធនាគារជាតិនៃកម្ពុជា ត្រូវបដិសេធចំពោះបញ្ជាទូទាត់ណាដែលគ្មានយថាភាពត្រឹមត្រូវ មិនមានព័ត៌មានលំអិតអំពីធនាគារឬអត្ថគាហកគ្រប់គ្រាន់ ឬល្មើសនឹងប្រកាសនេះ ឬប្រកាសស្តីពីនីតិវិធីប្រតិបត្តិការ ឬបញ្ហាណាផ្សេងៗទៀត ។

៧- បញ្ជាទូទាត់របស់ធនាគារដែលត្រូវបានលុបចោលឬបដិសេធមិនអាចយកមកអនុវត្តបានឡើយ លើកលែងតែមានការបញ្ជូនមកវិញជាបញ្ជាទូទាត់ថ្មីពីសំណាក់ធនាគារបញ្ជា ។

**ប្រការ ៧.-**

នីតិវិធីប្រតិបត្តិការអាចអនុញ្ញាតឱ្យធនាគារផ្ញើ ចាត់ថ្នាក់បញ្ជាទូទាត់មួយនៅក្រោមវិធាននេះជាការទូទាត់សងប្រាក់អាទិភាព ។ ជាកម្មវត្ថុនៃការមានមូលនិធិក្នុងគណនីទូទាត់របស់ធនាគារទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជានឹងព្យាយាមដំណើរការ ការទូទាត់សងប្រាក់អាទិភាព នេះនៅពេលបានទទួលបញ្ជាទូទាត់ដែលត្រូវបានចាត់ថ្នាក់នោះ ។

**ប្រការ ៨.-**

១- ចំពោះការទូទាត់ប្រាក់ជំពាក់រវាងធនាគារនៅទីបញ្ចប់នៃវដ្តផាត់ទាត់ពហុភាគីអន្តរធនាគារ បញ្ជីអំពីស្ថានភាពឥណពន្ធនិងឥណទានរបស់ធនាគារនីមួយៗ ត្រូវប្រគល់ទៅឱ្យធនាគារជាតិនៃកម្ពុជាក្នុងនាមធនាគារចូលរួមទាំងអស់ ។ ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តការទូទាត់ដោយ ÷

-ធ្វើការទូទាត់សងប្រាក់ធនាគារតែមួយ ពីធនាគារដែលមានស្ថានភាពឥណពន្ធ នូវចំនួនប្រាក់ឥណពន្ធរបស់ធនាគារ និងបន្ទាប់មក

-ធ្វើការទូទាត់សងប្រាក់ធនាគារតែមួយទៅឱ្យធនាគារដែលមានស្ថានភាពឥណទាន នូវចំនួនទឹកប្រាក់ឥណទានរបស់ធនាគារ ។

គ្មានខ្ទង់ឥណពន្ធ ឬ ឥណទានចំពោះគណនីទូទាត់នៅក្រោមប្រការនេះនឹងក្លាយជាស្ថាពរមិនអាចត្រឡប់វិញ និងមិនអាចបដិសេធបាននៅមុនពេលដែលរាល់ខ្ទង់ឥណពន្ធសមស្របត្រូវបានចុះកិច្ចបញ្ជិកាលើគណនីទូទាត់ របស់ធនាគារទាំងអស់ដែលស្ថិតក្នុងស្ថានភាពឥណពន្ធ និងរាល់ខ្ទង់ឥណទានសមស្របត្រូវបានចុះកិច្ចបញ្ជិកាលើគណនីទូទាត់របស់ធនាគារទាំងអស់ដែលស្ថិតក្នុងស្ថាន-ភាពឥណទានឡើយ ។ ការទូទាត់សងប្រាក់ធនាគារតែមួយនៅក្រោមកថាខណ្ឌនេះអាចត្រូវបានធ្វើឡើង ដើម្បីបញ្ចូល ឬទូទាត់ចេញ ពីគណនីហាមឃាត់ដែលបានរក្សានៅធនាគារជាតិនៃកម្ពុជា ។

២- ធនាគារជាតិនៃកម្ពុជា មិនត្រូវអនុវត្តការទូទាត់ក្រោមកថាខណ្ឌទី១ ទេ និងត្រូវស្វះស្វែងរកការបញ្ជាក់បន្ថែមដើម្បីបញ្ចប់ការទូទាត់ក្រោមកថាខណ្ឌទី១ លើកលែងតែ ÷

ក- ធនាគារជាតិនៃកម្ពុជាបានធ្វើការបញ្ជាក់ពីដំបូងថា ចំនួនប្រាក់សរុបជំពាក់ដោយធនាគារទាំងអស់ក្នុងស្ថានភាពឥណពន្ធ ស្មើនឹងចំនួនប្រាក់សរុបជំពាក់ចំពោះធនាគារទាំងអស់ក្នុងស្ថានភាពឥណទាន និង

ខ- ចំពោះធនាគារដែលស្ថិតក្នុងស្ថានភាពឥណពន្ធ មូលនិធិមានចំនួនគ្រប់គ្រាន់សំរាប់ទូទាត់ចេញពីគណនីទូទាត់ដើម្បីអនុវត្តការទូទាត់សងប្រាក់ធនាគារតែមួយក្នុងចំនួនប្រាក់ឥណពន្ធ ។

៣- វិធានគ្រប់គ្រងការផាត់ទាត់ពហុភាគីអន្តរធនាគារដែលត្រូវបានទូទាត់នៅក្រោមប្រការនេះ រួមទាំងនីតិវិធីសំរាប់ប្រើនៅពេលដែលមានការមិនគោរពតាមល័ក្ខខ័ណ្ឌនានាក្រោមកថាខណ្ឌទី២ ខ ត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជា ឬដោយការសំរបសំរួលរវាងធនាគារចូលរួមដែលមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៩.–**

១- ធនាគារជាតិនៃកម្ពុជាអាចអនុម័តនីតិវិធីប្រតិបត្តិការ រួមទាំងការកំណត់លក្ខណៈជាក់លាក់សំរាប់បញ្ជាទូទាត់ តារាងពេលវេលា និងនីតិវិធីសំរាប់គ្រប់គ្រងលើការជាត់ទាត់ និងការទូទាត់ ។

២- ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយជាបន្តបន្ទាប់ នូវតារាងកំរៃនិងសោហ៊ុយសេវានៅក្រោមប្រកាសនេះ ។

**ប្រការ ១០.–**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១១.–**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០០៦

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ១០
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "